មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

## សេចក្តីថ្លែងការណ៍របស់ ម.ស.ម.ក. ភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១

# ម.ស.ម.ក. សូមស្វាគមន៍ចំពោះសេចក្តីសម្រេចរបស់ អង្គការសហប្រជាជាតិ លើ និន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ និង ការចេញផ្សាយគោលការណ៍យ៉កយ៉ាកាតាជាភាសាខ្មែរ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និង មិនមាននិន្នាការនយោបាយ ដែលធ្វើការដើម្បីលើកកម្ពស់ និង ការពារលិទ្ធិប្រជាធិបតេយ្យ និង គោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា សូមស្វាគមន៍ចំពោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លើនិន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ( "សេចក្តីសម្រេច") ដែលគាំទ្រនូវសិទ្ធិស្មើគ្នាសម្រាប់មនុស្សទាំងអស់ដោយមិនគិតអំពីនិន្នាការភេទ។ សេចក្តីសម្រេចត្រូវបានអនុម័តនៅថ្ងៃទី១៧ មិថុនា ឆ្នាំ២០១១ ជាមួយនូវ ២៣សំលេង ទល់នឹង ១៩សំលេង ហើយជាសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលើកដំបូងទៅលើសិទ្ធិមនុស្សនៃស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ និង អ្នកផ្លាស់ប្តូរភេទ។ ប្រទេសកម្ពុជាមិនបានគាំទ្រនូវសេចក្តីសម្រេចនេះទេ។

ជាផ្នែកមួយទៀតនៃការខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៃអ្នកស្រលាញ់ភេទដូចជាគ្នា ថ្ងៃនេះ ម.ស.ម.ក. ចេញផ្សាយនូវការបកប្រែជាភាសាខ្មែរនៃ "គោលការណ៍យ៉កយ៉ាកាតាលើការអនុវត្តនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងទំនាក់ទំនងទៅលើ និន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ" ត្រូវបានទទួលស្គាល់ នៅខែវិច្ឆិកា ឆ្នាំ២០០៦ និង បានផ្តួចផ្តើមគំនិតដោយគណៈកម្មការចៅក្រមអន្តរជាតិ និង សេវាកម្មអន្តរជាតិសម្រាប់សិទ្ធិមនុស្ស តាំងនាមឲ្យអង្គការសិទ្ធិមនុស្ស ("គោលការណ៍យ៉កយ៉ាកាតា" )។ គោលការណ៍យ៉កយ៉ាកាតាគឺជាផ្នែកនៃគោលការណ៍ច្បាប់អន្តរជាតិ ដែលគោលបំណងរបស់ពួកគេគឺ ដើម្បីអះអាងនូវការចងភ្ជាប់មាត្រដ្ឋានច្បាប់អន្តរជាតិជាមួយនូវអ្វីដែលគ្រប់រដ្ឋដែលត្រូវតែស្របតាម ហើយទស្សនៈវិស័យរបស់ពួកគេនៅថ្ងៃអនាគត គឺមនុស្សទាំងអស់កើតដោយសេរី និង ភាពស្មើគ្នានៅក្នុងសេចក្តីថ្លៃថ្នូរ និង សិទ្ធិ។ គោលការណ៍យ៉កយ៉ាកាតា

(ជាភាសាអង់គ្លេស) គឺមានលើគេហទំព័រនៃ ម.ស.ម.ក. គេហទំព័រសិទ្ធិ www.sithi.org/temp.php?url=view_law.php&&id=183 ។

**អ្នកនាង ភោគ សុគន្ធារី អ្នកសម្របសម្រួលគម្រោង នៃ គម្រោង និន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ(សូជី) បានអត្ថាធិប្បាយថា៖**

"សេចក្តីសម្រេច និង គោលកាយ៉កយ៉ាកាតា គឺពិតជាមានការជះឥទ្ធិពលល្អទៅលើប្រទេសកម្ពុជាហើយនឹងអ្វីដែលក្រុមអ្នកស្រលាញ់ភេទដូចគ្នាបានយល់ឃើញ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿថាការផ្តួចផ្តើមគំនិតតាមលក្ខណៈផ្លូវច្បាប់ដើម្បីបំពេញនូវសក្តានុពល និង មានការជះឥទ្ធិពលយ៉ាងខ្លាំង ជាផ្នែកសំខាន់ដែលរាជរដ្ឋាភិបាលកម្ពុជា គួរតែបញ្ចេញសំលេងគាំទ្រទៅលើសេចក្តីសម្រេចទាំងពីរខាងលើនេះ និងសម្រាប់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា នៅក្នុងប្រទេសកម្ពុជាបើមិនដូច្នោះទេ នឹងបន្តឲ្យមានការឈឺចាប់ក្នុងការរើសអើង អំពើហិង្សា និង ការរំលោភសិទ្ធិមនុស្ស។ នេះគឺជាពេលវេលាដ៏សំខាន់ដែលរាជរដ្ឋាភិបាលទទួលស្គាល់ ការទទួលយកការអត់ឱនជាសកលចំពោះអ្នកស្រលាញ់ភេទដូចគ្នា និង ទទួលយកជំហ៊ានវិជ្ជមានឆ្ពោះទៅកាន់ការបញ្ចប់ភាពរើសអើងនៅក្នុងប្រទេសកម្ពុជា"

**"ចប់"**

**សម្រាប់ពត៌មានបន្ថែម សូមទាក់ទងមកកាន់ អ្នកនាង ភោគ សុគន្ធារី តាមរយៈទូរសព្ទលេខ +៨៥៥ (0) ៧៨ ៦៤ ០៩ ០០ ឬ សារអេឡិចត្រូនិច sokuntheary@cchrcambodia.org ។**

**<u>បណ្ណាធិការ</u>**

ម.ស.ម.ក. ត្រូវបានបង្កើតឡើងនូវឆ្នាំ២០០២។

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទទួលបានពានរង្វាន់សិទ្ធិមនុស្ស រីប៊ុក ចំពោះស្នាដៃរបស់លោកក្នុងការលើកស្ទួយសេរីភាពបញ្ចេញមតិក្នុងឆ្នាំ២០០៧។

ម.ស.ម.ក. គឺជាសមាជិករបស់ ដៃគូសន្ធានាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលដើម្បីការសំដែងមតិដោយសេរី។